# របាយការណ៍

# និន្នាការសេដ្ឋកិច្ច-សង្គម

## ប្រចាំខែ ឧសភា ឆ្នាំ ២០២៤

# Socio-Economic Trends Report

## May 2024

រៀបចំដោយ
នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច
អគ្គនាយកដ្ឋានគោលនយោបាយ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



# មាតិកា


ទំព័រ

**ខ្លឹមសារសង្ខេប /Executive summary** ១

**១. និន្នាការសេដ្ឋកិច្ចកម្ពុជា /Cambodia economic trends** ៤

១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ /Consumer price index ៤

១.២. វិស័យពាណិជ្ជកម្ម /Trade ៥

១.៣. វិស័យវិនិយោគឯកជន /Private investment ៨

១.៤. ទេសចរណ៍ក្នុងតំបន់អង្គរ /Tourism in Angkor Park ៩

១.៥. វិស័យសំណង់ /Construction ១០

**២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** ១១

២.១. ថ្លៃប្រេង ( Crude oil price: Brent, WTI ) ១១

២.២. ថ្លៃអង្ករ ( Rice price: 5%,25% broken ) ១២

**៣. ឧបសម្ព័ន្ធ** ១៤

## **ខ្លឹមសារសង្ខេប** / Executive summary

*<u>តាមរយៈការតាមដានសូចនាករសេដ្ឋកិច្ច-សង្គមសំខាន់ៗ ក្នុងខែឧសភា ឆ្នាំ២០២៤ នេះ មាននិន្នាការដូចខាងក្រោម៖</u>*

**១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ ក្នុងខែឧសភា ឆ្នាំ២០២៤ កើនឡើង ០,៨% ធៀបនឹងខែមុន និង១,១% ធៀបនឹងខែឧសភា ឆ្នាំ២០២៣។** សន្ទស្សន៍ថ្លៃក្រុមទំនិញប្រើប្រាស់ និងសេវាកម្មសំខាន់ៗ ដែលមានកំណើនធៀបនឹងខែមុន រួមមាន៖ សន្ទស្សន៍ថ្លៃក្រុមអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង កើនឡើង ១,៤%, សន្ទស្សន៍ថ្លៃក្រុមសំលៀកបំពាក់និងស្បែកជើង កើនឡើង ១,៤%, សន្ទស្សន៍ថ្លៃក្រុមភោជនីយដ្ឋាន កើនឡើង ០,៦%, និងសន្ទស្សន៍ថ្លៃក្រុមការសិក្សា កើនឡើង ០,៤%។ ធៀបនឹងខែឧសភា ឆ្នាំ២០២៣, សន្ទស្សន៍ថ្លៃក្រុមការសិក្សា កើនឡើង ២,៩%, សន្ទស្សន៍ថ្លៃក្រុមសំលៀកបំពាក់និងស្បែកជើង កើនឡើង ២,៥%, និងសន្ទស្សន៍ថ្លៃក្រុមអាហារ និងភេសជ្ជៈ មិនមែនជាតិស្រវឹង កើនឡើង ១,៦%។

**២. ទំហំពាណិជ្ជកម្មសរុបជកមាសក្នុងខែឧសភា ឆ្នាំ២០២៤ សម្រេចបានកំណើនល្អឡើងវិញគួរឱ្យកត់សម្គាល់ បើទោះជាមានផលវិបាកពីវិបត្តិសកល បញ្ហាបម្រែបម្រួលអាកាសធាតុ និងការថមថយតាមរដូវកាលនៃការនាំចេញ កសិផលបន្តិចក្តី។** ជាក់ស្តែង ក្នុងខែឧសភា ឆ្នាំ២០២៤ នេះ ការនាំចេញ កើនឡើង ១៨,៥% និងការនាំចូល កើនឡើង ៧,១% ធៀបនឹងខែមុន, ខណៈដែលគិតត្រឹម ៥ខែដើមឆ្នាំ២០២៤ ការនាំចេញ កើនឡើង ១៥,៤% និងការនាំចូល កើនឡើង ១១,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ បន្ថែមលើនេះ ឱនភាពនៃតុល្យភាពជញ្ជីងពាណិជ្ជកម្មក្នុងរយៈពេល ៥ខែដូចគ្នាកាលពីឆ្នាំមុន បានធ្លាក់ចុះពីទំហំ ១ ៣៧៨ លានដុល្លារ មកត្រឹម ១ ១៩៣ លានដុល្លារ ថយចុះ ១៣,៤% ធៀបនឹង ៥ខែដូចគ្នាឆ្នាំមុន ដែលការណ៍នេះ បានបង្ហាញពីនិន្នាការនៃការប្រើប្រាស់ផលិតផលក្នុងស្រុក និងសន្ទុះនៃការនាំចេញប្រសើរទៅកាន់ទីផ្សារអន្តរជាតិ។

**៣. ក្នុងខែឧសភា ឆ្នាំ២០២៤ ចំនួនភ្ញៀវទេសចរបរទេសចូលទស្សនាតំបន់អង្គរបន្តធ្លាក់ចុះធៀបនឹងខែមេសា ឆ្នាំ ២០២៤ ដោយសារកត្តារដូវកាលការបិទវិស្សមកាលទេសចរណ៍ (Low-Season) ប៉ុន្តែបានកើនឡើងបើគិតសរុប រយៈពេល៥ខែដើមឆ្នាំ២០២៤។** ជាក់ស្តែង ក្នុងខែឧសភា ឆ្នាំ២០២៤ តំបន់អង្គរទទួលបានភ្ញៀវទេសចរបរទេសចំនួន ៥០ ៨៧៩ នាក់ ធ្លាក់ ៣១,១% ធៀបនឹងខែមេសា ឆ្នាំ២០២៤ និងចំណូលពីការលក់បណ្ណពីគ្រឹះស្ថានអង្គរមានប្រមាណ ២,២៨ លានដុល្លា ធ្លាក់ ៣៦,១% ធៀបនឹងខែមេសា ឆ្នាំ២០២៤។ រយៈពេល៥ខែដើមឆ្នាំ២០២៤ ភ្ញៀវទេសចរអន្តរជាតិ ចូលទស្សនាអង្គរបានកើនឡើង ៣៧,០% ទន្ទឹមនឹងចំណូលពីការលក់សំបុត្ររបស់គ្រឹះស្ថានអង្គរបានកើនឡើង ៣៨,២%។

**៤. យោងតាមទិន្នន័យខែឧសភា ឆ្នាំ២០២៤ ទំហំផ្ទៃក្រឡាគម្រោងសាងសង់ និងទុនវិនិយោគឡើងវិញបន្តិចធៀប នឹងខែមុន ខណៈដែលចំនួនសាងសង់មានការធ្លាក់ចុះ ប៉ុន្តែការនាំចូលនិងការផលិតគ្រឿងសំណង់មានការកើនឡើង ។** ក្នុងខែឧសភាឆ្នាំ២០២៤ គម្រោងសំណង់ទទួលបានការអនុញ្ញាតសាងសង់សរុបមាន ២៣១ គម្រោង ធ្លាក់ ១៤,១%, មានផ្ទៃក្រឡា ១ ៣៧៣ ពាន់ម៉ែត្រការ៉េ កើន ៤៩,៧%, ប្រើប្រាស់ទុន ៧៣៩,៧ លានដុល្លារ កើន ១៥៩,៩% ធៀបនឹងខែមុន។ រយៈពេល៥ខែដើមឆ្នាំ២០២៤ ការអនុម័តគំរោងសាងសង់ជាទឹកប្រាក់បានថយចុះ ២០,២% ប៉ុន្តែទន្ទឹមនឹងនេះ ការនាំចូល

គ្រឿងសំណង់បានកើនឡើង ២៣,១% និងការផលិតស៊ីម៉ងត៍ក្នុងស្រុកបានកើនឡើង ៤,៧% ប្រមាណ ៣,៥ លានតោន ដែលជាធាតុបង្ហាញពីការកើនឡើងនៃវិស័យនេះ។

**៥. ស្ថានភាពគម្រោងវិនិយោគឯកជនដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែឧសភា ឆ្នាំ២០២៤ មានការថយចុះធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងខ្ពស់គិតសរុបរយៈពេល៥ខែដើមឆ្នាំ២០២៤។** ជាក់ស្តែង ចំនួនគម្រោងវិនិយោគក្នុងខែឧសភា ឆ្នាំ២០២៤ មាន ២៥ គម្រោង ដែលបានប្រើប្រាស់ទុនវិនិយោគសរុបចំនួន ២៤៦ លានដុល្លារ ថយចុះ ២០,៤% និងបង្កើតការងារថ្មីចំនួន ១៥ ១៣៩ កន្លែង ថយចុះ ៣៥,២៥% ធៀបនឹងខែមុន។ ជាសរុបរយៈពេល៥ខែដើមឆ្នាំ២០២៤ ការអនុម័តវិនិយោគទុនបរទេសបានកើនឡើង ៣២៥,៤% ក្នុងនោះអនុម័ត កម្លាំងពលកម្មថ្មី មានកំណើន ៧៦,០%។

**៦. ក្នុងខែឧសភា ឆ្នាំ២០២៤, នៅទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ថ្លៃប្រេងជាមធ្យម ថយចុះ ធៀបនឹងខែមុន ខណៈដែល ថ្លៃអង្ករជាមធ្យម ហាក់នៅមានកំណើន។** ធៀបនឹងខែមុន, ថ្លៃប្រេងឥន្ធនៈក្នុងស្រុក និងថ្លៃប្រេងឆៅ អន្តរជាតិ ថយ ៣,១% និង ៧,៥% រៀងគ្នា, ប៉ុន្តែថ្លៃអង្ករក្នុងស្រុក និងអន្តរជាតិ កើន ១៣,៨% និង ២១,៧% រៀងគ្នា។ ជាលទ្ធផល ក្នុងរយៈពេល៥ខែដើមឆ្នាំ២០២៤ ថ្លៃប្រេងឆៅអន្តរជាតិ, ថ្លៃអង្ករក្នុងស្រុក, និងថ្លៃអង្ករអន្តរជាតិ នៅខ្ពស់នៅឡើយធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ដោយបានកើនឡើង ៤,៥%, ១២,១%, និង២៦,២% រៀងគ្នា។ យ៉ាងណាមិញ ថ្លៃប្រេងឥន្ធនៈ និងថ្លៃអង្ករក្នុងស្រុក មិនទាន់ឡើងដល់ចំណុចគួរឱ្យបារម្ភនៅឡើយ។

*សូចនាករសេដ្ឋកិច្ចសំខាន់ៗក្នុងខែឧសភា និងរយៈពេល៥ខែ ឆ្នាំ២០២៤ បានបង្ហាញពីសញ្ញាណកាន់តែល្អជាបន្តបន្ទាប់ ជាពិសេសលើវិស័យពាណិជ្ជកម្មអន្តរជាតិ និងទេសចរណ៍ ស្របពេលដែលស្ថានភាពអតិផរណាកំពុងវិលត្រលប់មកស្ថានភាពល្អប្រសើរឡើងវិញ, ប៉ុន្តែសកម្មភាពសាងសង់មានការធ្លាក់ចុះបន្តិច។ ការធ្លាក់ចុះនៃសកម្មភាពក្នុងខែនេះគឺបណ្តាលមកពីកត្តារដូវកាល តែសកម្មភាពទាំងនេះ នឹងរើបឡើងវិញកាន់តែល្អប្រសើរជាបន្តបន្ទាប់នៅខែខាងមុខ។ ផ្អែកលើការតាមដានជាប់ជាប្រចាំទាំងសេដ្ឋកិច្ចក្នុងប្រទេស និងសេដ្ឋកិច្ចសកល សកម្មភាពសេដ្ឋកិច្ចកម្ពុជា នឹងរើបឡើងវិញជាបណ្តើរៗជាពិសេសក្នុងវិស័យសេវាកម្ម និងកសិកម្ម។*

| តារាង ១៖ ស្ថិតិសង្ខេបសេដ្ឋកិច្ចតាមវិស័យ ប្រចាំខែឧសភា ឆ្នាំ២០២៤ | | | | | | |
|---|---|---|---|---|---|---|
| | | ឯកតា | តម្លៃ | កើន/ថយ | | |
| | | | | ខែមុន | ឧសភា ឆ្នាំមុន | ៥ខែ ដើមឆ្នាំមុន |
| I | **សន្ទស្សន៍ថ្លៃ និងថ្លៃទំនិញ** | | | | | |
| | -សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ | សន្ទស្សន៍ | 203.55 | 0.80% | 1.10% | 0.17% |
| | -សន្ទស្សន៍ថ្លៃម្ហូបអាហារ | សន្ទស្សន៍ | 258.24 | 1.45% | 1.60% | 0.32% |
| | -ថ្លៃប្រេងសាំង | រៀល/លីត្រ | 4,317 | -3.36% | 4.44% | 0.70% |
| | -ថ្លៃប្រេងម៉ាស៊ូត | រៀល/លីត្រ | 4,067 | -2.79% | 5.17% | -1.26% |
| | -ថ្លៃអង្ករផ្កាម្លិះ | រៀល/គ.ក | 4,059 | 4.27% | 10.23% | 6.56% |
| | -ថ្លៃអង្ករផ្កាខ្ញី | រៀល/គ.ក | 3,310 | -1.76% | 17.69% | 23.13% |
| | -ថ្លៃអង្ករនាងមិញ | រៀល/គ.ក | 3,064 | 2.12% | 14.71% | 8.48% |
| | -ថ្លៃសាច់ត្រី | រៀល/គ.ក | 11,103 | 2.59% | 8.88% | 7.07% |
| | -ថ្លៃសាច់ជ្រូក | រៀល/គ.ក | 24,313 | 0.52% | 8.61% | 8.03% |
| | -ថ្លៃប្រេងឆៅ (Brent) | USD/BBL | 82.00 | -8.95% | 8.32% | 4.29% |
| | -ថ្លៃប្រេងឆៅ (WTI) | USD/BBL | 78.81 | -6.83% | 10.09% | 4.00% |
| | -ថ្លៃអង្ករថៃ (ប្រភេទអង្ករបាក់ ៥%) | USD/MT | 628.00 | 6.08% | 23.14% | 24.88% |
| | -ថ្លៃអង្ករវៀតណាម (ប្រភេទអង្ករបាក់ ៥%) | USD/MT | 567.97 | -0.62% | 20.71% | 31.23% |
| II | **ពាណិជ្ជកម្មកម្ពុជា** | | | | | |
| | *ការនាំចេញទំនិញសរុប (ដកមាស)* | **លានដុល្លារ** | 2,067.17 | 18.51% | 15.96% | 15.37% |
| | -ផលិតផលវាយនភណ្ឌ | លានដុល្លារ | 1,187.51 | 46.80% | 31.77% | 20.73% |
| | -ផលិតផលមិនមែនវាយនភណ្ឌ | លានដុល្លារ | 879.66 | 23.5% | -0.20% | 10.73% |
| | -ក្នុងនោះ ផលិតផលកសិកម្ម* | លានដុល្លារ | 181.25 | -48.7% | -9.49% | -10.75% |
| | *ការនាំចូលសរុប (ដកមាស)* | **លានដុល្លារ** | 2,601.93 | 7.09% | 19.24% | 11.45% |
| | -ប្រេងឥន្ធនៈ | លានដុល្លារ | 289.66 | 5.13% | 51.75% | 31.23% |
| | -វត្ថុធាតុដើមកាត់ដេរ | លានដុល្លារ | 597.22 | 19.36% | -85.65% | -87.85% |
| | -គ្រឿងសំណង់** | លានដុល្លារ | 229.03 | 24.50% | 29.40% | 23.05% |
| | -វត្ថុធាតុដើមកសិកម្ម (ជីកសិកម្ម) | លានដុល្លារ | 36.58 | 36.93% | 29.43% | 7.90% |
| | -គ្រឿងហូបចុក (Food stuff) | លានដុល្លារ | 60.50 | -0.20% | 14.05% | 13.54% |
| III | **ទេសចរ** | | | | | |
| | -ភ្ញៀវទេសចរបរទេសទិញសំបុត្រពីគ្រឹះស្ថានអង្គរ | នាក់ | 50,879 | -31.10% | 11.19% | 36.98% |
| | -ចំណូលពីសំបុត្ររបស់គ្រឹះស្ថានអង្គរ | ដុល្លារ | 2 289 358 | -32.45% | 12.52% | 38.22% |
| IV | **សាងសង់** | | | | | |
| | -ចំនួនគម្រោងដែលទទួលបានការអនុញ្ញាតសាងសង់ | គម្រោង | 231.00 | -14.13% | 36.69% | -9.09% |
| | -ផ្ទៃក្រឡាសាងសង់ | ម៉ែត្រការ៉េ | 1,373,406.59 | 49.66% | 37.03% | -22.60% |
| | -ទំហំទឹកប្រាក់សាងសង់ | លានដុល្លារ | 739.71 | 159.90% | 97.28% | -20.24% |
| V | **គម្រោងវិនិយោគ** | | | | | |
| | -គម្រោងវិនិយោគឯកជន | គម្រោង | 25.00 | 13.64% | 150.00% | 104.00% |
| | -ទុនវិនិយោគសរុប | លានដុល្លារ | 246.30 | -20.44% | 308.72% | 325.45% |
| | -កម្លាំងពលកម្មថ្មី | នាក់ | 15,139.00 | -35.25% | 10.22% | 76.03% |

***សម្គាល់*** ៖ *ផលិតផលកសិកម្ម រួមមាន៖ ស្រូវ, ដំឡូងមី, ពោត, សណ្តែក, ចេក, ស្វាយ, ស្វាយចន្ទី, កៅស៊ូ, ស្ករ, ផលិតផលជលផល និងផលិតផលកសិកម្មដទៃទៀត

**សំណង់ រួមមាន៖ គ្រឿងបរិក្ខារសំណង់, ស៊ីម៉ងត៍ និងដែកថែប។

# ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

## ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

តាមរយៈទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ ក្នុងខែឧសភា ឆ្នាំ២០២៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មនៅរាជធានីភ្នំពេញ កើន ០,៨% ធៀបនឹងខែមុន និង កើន ១,១% ធៀបនឹងខែឧសភា ឆ្នាំ២០២៣។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្មសំខាន់ៗ ដែលមានការកើនឡើងធៀបនឹងខែមុនរួមមាន៖ សន្ទស្សន៍ថ្លៃក្រុមអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង កើន ១,៤%, សន្ទស្សន៍ថ្លៃក្រុមសំលៀកបំពាក់និងស្បែកជើង កើន ១,៤%, សន្ទស្សន៍ថ្លៃក្រុមភោជនីយដ្ឋាន កើន ០,៦%, និងសន្ទស្សន៍ថ្លៃក្រុមការសិក្សា កើន ០,៤%។

ធៀបនឹងខែឧសភា ឆ្នាំ២០២៣, សន្ទស្សន៍ថ្លៃក្រុមទំនិញប្រើប្រាស់និងសេវាកម្ម ដែលមានកំណើនរួមមាន៖ សន្ទស្សន៍ថ្លៃក្រុមការសិក្សា កើន ២,៩%, សន្ទស្សន៍ថ្លៃក្រុមសំលៀកបំពាក់និងស្បែកជើង កើន ២,៥%, សន្ទស្សន៍ថ្លៃក្រុមអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង កើន ១,៦%, និងសន្ទស្សន៍ថ្លៃក្រុមភោជនីយដ្ឋាន កើន ០,៨%។ ទន្ទឹមនេះ សន្ទស្សន៍ថ្លៃក្រុមដឹកជញ្ជូន ថយ ០,៤% ធៀបនឹងខែឧសភា ឆ្នាំ២០២៣ ប៉ុន្តែថ្លៃប្រេងសាំងធម្មតា និងថ្លៃប្រេងម៉ាស៊ូតកើនឡើង ៤,៤% និង ៥,២% រៀងគ្នា ធៀបនឹងខែឧសភា ឆ្នាំ២០២៣។







*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងពាណិជ្ជកម្ម*

## ១.២. វិស័យពាណិជ្ជកម្ម / Trade

ទំហំពាណិជ្ជកម្មសរុបដកមាសក្នុងខែឧសភា ឆ្នាំ២០២៤ សម្រេចបានកំណើនល្អឡើងវិញ ពោលគឺបានកើនឡើងប្រមាណ ៤៩៥ លានដុល្លារធៀបនឹងខែមុន, ដែលស្មើនឹងទំហំប្រចាំខែសរុប ៤ ៦៦៩ លានដុល្លារ កើន ១១,៩% ធៀបនឹងខែមុន។ បន្ថែមលើនេះ បើធៀបក្នុងខែដូចគ្នាកាលពីឆ្នាំមុន ទំហំនេះ កើនឡើងប្រមាណ ១៧,៨% ដែលការណ៍នេះ នាំឱ្យទំហំពាណិជ្ជកម្មសរុបក្នុងរយៈពេល ៥ខែដើមឆ្នាំ២០២៤ កើនដល់ ២១ ៣៤០ លានដុល្លារ ស្មើនឹងកំណើន ១៣,៣% ធៀបនឹងរយៈពេល ៥ខែដូចគ្នាឆ្នាំមុន។




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

### ក. ការនាំចេញ៖

ការនាំចេញទំនិញដកមាសក្នុងខែឧសភា ឆ្នាំ២០២៤នេះ បានបង្ហាញពីកំណើនល្អគួរឱ្យកត់សម្គាល់ឡើងវិញ ពោលគឺជាអត្រានៃកំណើន ដែលមាននិន្នាការប្រសើរជាងឆ្នាំមុន (លើសពីមូលដ្ឋាននៃនិន្នាការរដូវកាលកន្លងមក (Seasonal trend)។ ការណ៍នេះក៏ដោយសារ៖ (១) កត្តារដូវកាល (Seasonal trend) ដែលតែងមានកំណើន

ក្នុងខែឧសភា បន្ទាប់ពីវិស្សមកាលរយៈពេលខ្លីកាលពីខែមេសា កន្លងទៅ (២) សន្ទុះនៃការបញ្ជាទិញខ្ពស់នៃផលិតផលកាត់ដេរ (៣) ការនាំចេញផលិតផលថ្មីៗបន្ថែម រួមមាន ឧបករណ៍អេឡិចត្រូនិក សំបកកង់រថយន្ត ខ្សែចម្លងនិងអ៊ុបទិក និងគ្រឿងសង្ហារិម ជាដើម។ ជាក់ស្តែង ក្នុងខែឧសភា ឆ្នាំ២០២៤ នេះ ការនាំចេញសម្រេចបាន ២ ០៦៧ លានដុល្លារ កើនឡើង ១៨,៥% ធៀបនឹងខែមុន ក្នុងនោះ ផលិតផលកាត់ដេរ កើន ៤៦,៨%, ផលិតផលកម្មន្តសាលមិនមែនកាត់ដេរ កើន ២៣,៥% ប៉ុន្តែការនាំចេញកសិផល បានធ្លាក់ចុះវិញប្រមាណ ៤៨,៧% ធៀបនឹងខែមុន ដោយសារកសិផលសំខាន់ៗមួយចំនួន រួមមាន ស្រូវ និងដំឡូងមី ជាដើម បានប្រមូលផលរួចរាល់ និងកំពុងចាប់ផ្តើមបង្កបង្កើនផលឡើងវិញ។ ការនាំចេញផលិតផលកាត់ដេរមានទំហំ ១ ១៨៨ លានដុល្លារ ក្នុងនោះ ការនាំចេញសម្លៀកបំពាក់ មានជាង ៣០,៩% នៃទំហំនាំចេញសរុប ដែលមានកំណើន ៥២,៣% ធៀបនឹងខែមុន។ ការនាំចេញកម្មន្តសាលមិនមែនកាត់ដេរ មានប្រមាណជាង ៦៨៤ លានដុល្លារ ក្នុងនោះការនាំចេញផលិតផលសូឡា គ្រឿងសង្ហារិម ផលិតផលឈើ និងកង់ មានកំណើនឡើងវិញ ខណៈដែលការនាំចេញ សំបកកង់រថយន្តបានថយចុះបន្តិច។ យ៉ាងណាមិញ, បើធៀបនឹងខែឧសភា ឆ្នាំមុន ការនាំចេញនៅតែបង្ហាញពីកំណើនរឹងមាំ ពោលគឺ កើន ១៦% ធៀបនឹងខែមេសា ឆ្នាំមុន, ទន្ទឹមនឹងនេះ ទំហំនាំចេញរយៈពេល ៥ខែដើមឆ្នាំនេះ សម្រេចបានប្រមាណជាង ១០ ០៧៣ លានដុល្លារ កើន ១៥,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

*ក្រាហ្វិក ៥៖ ទំហំទឹកប្រាក់នាំចេញដកមាសគិតត្រឹមខែឧសភា ឆ្នាំ២០២៤ (គិតជាលានដុល្លារ)*




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

*ក្រាហ្វិក ៦៖ ទីផ្សារអាមេរិក អឺរ៉ុប និងអាស៊ាន ជាទីផ្សារនាំចេញធំរបស់កម្ពុជាក្នុងខែឧសភា*




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

តារាង ២. ទំហំទឹកប្រាក់ និងចំណែក% នៃនាំចេញតាមមុខទំនិញសំខាន់ៗ ក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០២៤ (គិតជាលានដុល្លារអាមេរិក)

| ទំនិញ (គិតជាលានដុល្លារ) | ទំហំទឹកប្រាក់នាំចេញ | សមាមាត្រជាភាគរយ |
|---|---|---|
| វាយនភណ្ឌ | 4,894 | 48.1% |
| កង់ | 131 | 1.3% |
| អង្ករ | 223 | 2.2% |
| ដំឡូងមី | 485 | 4.8% |
| ជ័រកៅស៊ូ | 185 | 1.8% |
| ទំនិញផ្សេងៗ | 4,156 | 40.8% |
| សរុបជកមាស | 10,073 | 98.9% |
| ទំនិញនាំចេញជកមាសមាន ៩៨,៩% នៃទំនិញនាំចេញសរុប | | |

*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

**<u>ខ. ការនាំចូល</u>** ការនាំចូលទំនិញជកមាស ក្នុងខែឧសភា ឆ្នាំ២០២៤ ក៏សម្រេចបានកំណើនល្អផងដែរធៀបនឹងខែមុន ដោយសារតម្រូវការសម្ភារប្រើប្រាស់ចាំបាច់រយៈពេលវែង (Durable Goods) កើនឡើង និងការនាំចូលបំពេញបន្ថែមវត្ថុធាតុដើមក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់នៃផលិតកម្មក្នុងស្រុកច្រើន។ តួយ៉ាង, ការនាំចូលក្រណាត់ នៅតែមានកំណើនល្អ (កើន ១៩,៤%), គ្រឿងសំណង់ហក់ឡើងខ្ពស់ជាងខែកន្លងទៅ (កើន ២៤,៥%), យានយន្តមានកំណើនឡើងវិញ (កើន ១២,៤%), គ្រឿងម៉ាស៊ីន (កើន ២០,៦%) និងផលិតផលនាំចូលផ្សេងទៀត កើនឡើង ១,៣% ខណៈដែលគ្រឿងម្ហូបអាហារ សម្លៀកបំពាក់ថ្មី ចាស់ ភេសជ្ជៈ និងឧបករណ៍អេឡិចត្រូនិក បានធ្លាក់ចុះ ០,៥%, ២,៧%, ៨,៦% និង ៦,២% រៀងគ្នាធៀបនឹងខែមុន ក៏ដោយសារការចំណាយច្រើនកាលពីខែមុនរបស់អតិថិជន បានធ្វើឱ្យតម្រូវការក្នុងទិញរបស់ទាំងនេះ ថយចុះ។ បន្ថែមលើនេះ ការនាំចូលក្នុងខែឧសភា ឆ្នាំនេះ មានទំហំ ២ ៦០២ លានដុល្លារ កើនឡើង ៧,១% ធៀបនឹងខែមុន និង ១៩,២% ធៀបនឹងខែឧសភាឆ្នាំមុន, ខណៈបើគិតត្រឹម ៥ខែដើមឆ្នាំ២០២៤នេះ ក៏នៅតែសម្រេចបានកំណើនល្អផងដែរក្នុងរង្វង់ ១១,៤%។

ក្រាហ្វិក ៧៖ ទំហំទឹកប្រាក់នាំចូលជកមាសក្នុងខែឧសភា (គិតជាលានដុល្លារ) និងកំណើនធៀបខែ, ធៀបឆ្នាំ



*ក្រាហ្វិក ៨៖ ទីផ្សារចិន, អាស៊ាន និង អឺរ៉ុបបានរួមចំណែកធំក្នុងទីផ្សារនាំចូលសរុបរបស់កម្ពុជាក្នុងខែឧសភា*




*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

តារាង ៣. ទំហំទឹកប្រាក់ និងចំណែក% នៃការនាំចូលតាមមុខទំនិញសំខាន់ៗក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០២៤ (គិតជាលានដុល្លារអាម៉េរិក)

| **ទំនិញ (គិតជាលានដុល្លារ)** | **ទំហំទឹកប្រាក់នាំចេញ** | **សមាមាត្រជាភាគរយ** |
|---|---|---|
| ក្រណាត់ | 2,226 | 19.5% |
| គ្រឿងសំណង់ | 926 | 8.1% |
| យានយន្ត | 485 | 4.2% |
| ប្រេងឥន្ធនៈ | 1,287 | 11.3% |
| ទំនិញផ្សេងទៀត | 6,343 | 55.5% |
| សរុបដកមាស | 11,266 | 98.6% |
| ទំនិញនាំចូលដកមាសមាន ៩៨,៦% នៃទំនិញនាំចូលសរុប | | |

*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

*ប្រភព៖ ស្ថិតិទំហំពាណិជ្ជកម្មអន្តរជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

**<u>គ. សរុបស្ថានភាពពាណិជ្ជកម្ម៖</u>** ពាណិជ្ជកម្មកម្ពុជា បាននិងកំពុងមានកំណើនល្អប្រសើរ បើទោះជាមានផលវិបាកពីវិបត្តិសកល បញ្ហាបម្រែបម្រួលអាកាសធាតុ និងការថមថយតាមរដូវកាលនៃការនាំចេញកសិផលបន្តិចក្តី។ ជាក់ស្តែង ក្នុងខែឧសភា នេះ ទាំងការនាំចេញ នាំចូល បានកើន ព្រមគ្នាធៀបនឹងខែមុន ខណៈដែល គិតត្រឹម ៥ខែដើមឆ្នាំ២០២៤ ទំហំនេះ ក៏នៅតែសម្រេចបានកំណើនរឹងមាំផងដែរ ដោយសារបរិយាកាសធុរកិច្ចកាន់តែទាក់ទាញ ដែលជម្រុញឱ្យវិនិយោគិនកាន់តែមានសុទិដ្ឋិនិយមក្នុងការពង្រីកទំហំនាំចូល និងបង្កើនលទ្ធភាពក្នុងការនាំចេញ។ បន្ថែមលើនេះ ឱនភាពនៃតុល្យភាពជញ្ជីងពាណិជ្ជកម្មក្នុងរយៈពេល ៥ខែដូចគ្នាកាលពីឆ្នាំមុន បានធ្លាក់ចុះពីទំហំ ១ ៣៧៨ លានដុល្លារ មកត្រឹម ១ ១៩៣ លានដុល្លារ ដែលបានបង្ហាញពីកម្លាំងនៃកំណើននាំចេញ ក៏ដូចជាការបញ្ជាក់ពីលទ្ធភាពដែលកម្ពុជាមាននិន្នាការប្រើប្រាស់ផលិតផលក្នុងស្រុកកាន់តែច្រើន។ បន្ថែមលើនេះ កំណើននៃការនាំចូលផលិតផលវត្ថុធាតុដើម ក្រណាត់ ផលិតផលឥន្ធនៈ គ្រឿងសំណង់ និងទំនិញនាំចូលផ្សេងទៀត គឺជាសញ្ញាណល្អនៃកំណើន ក្នុងការនាំចេញផលិតផលកាត់ដេរ និងផលិតផលកម្មន្តសាលមិនមែនកាត់ដេរក្នុងខែបន្ទាប់ទៀត។ ដូចនេះ ដោយផ្អែកលើការតាមដានជាប់ជាប្រចាំ, ស្ថានភាពពាណិជ្ជកម្មរបស់កម្ពុជា រំពឹងថា នឹងនៅតែបន្តសម្រេចបានកំណើនល្អក្នុងខែបន្តបន្ទាប់ទៀតជាមួយនឹងសុទិដ្ឋិនិយមខ្ពស់ក្នុងឆ្នាំ២០២៤។

## ១.៣. ស្ថានភាពវិនិយោគ / Investment

នៅក្នុងខែឧសភា ឆ្នាំ២០២៤ ប្រទេសកម្ពុជាទទួលបានគម្រោងវិនិយោគសរុប ២៥ គម្រោង ដែលក្នុងនោះគម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ៨ គម្រោង និងក្រៅតំបន់សេដ្ឋកិច្ចពិសេសមានគម្រោងថ្មីចំនួន ១៧ គម្រោង។ ការវិនិយោគនេះបានប្រើប្រាស់ទុនប្រមាណ ២៤៦,៣ លានដុល្លារ និងមានលទ្ធភាពបង្កើតការងារថ្មីចំនួន ១៥ ១៣៩ នាក់។ បើប្រៀបធៀបទៅនឹងខែមេសា ឆ្នាំ២០២៤ ចំនួនគម្រោងកើនឡើង ៣ គម្រោង, ខណៈទំហំទុន និង លទ្ធភាពបង្កើតការងារថ្មីបានធ្លាក់ចុះ ប្រមាណ ២០,៤% និង ៣៥,៣% រៀងគ្នា។ ទោះជាយ៉ាងនេះក្តី ស្ថានភាពវិនិយោគក្នុងខែឧសភា

ឆ្នាំ២០២៤ ហាក់មានវឌ្ឍនភាពល្អប្រសើរ ធៀបនឹងខែឧសភា ឆ្នាំ២០២៣ ក្នុងនោះ គម្រោងវិនិយោគឯកជន កើន ១៥០%, ទុនវិនិយោគសរុប កើន ៣០៨,៧%, និងកម្លាំងពលកម្មថ្មី កើន ១០,២% រៀងគ្នា។

ជាលទ្ធផល ក្នុងរយៈពេល៥ខែ ឆ្នាំ២០២៤ មានគម្រោងវិនិយោគសរុប ១៥៣ គម្រោង, ដែលបានប្រើប្រាស់ទុនសរុប ២ ៧៦០ លានដុល្លារ និងលទ្ធភាពបង្កើតការងារថ្មី ចំនួន ១៤៥ ៦២១ កន្លែង។ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ចំនួនគម្រោងវិនិយោគ កើន ៧៨ គម្រោង (ស្មើនឹង ១០៤%), ទុនវិនិយោគ កើន ៣២៥,៣%(ស្មើនឹង ២ ១១១ លានដុល្លារ), ការងារកើន ៧៦ %(ស្មើនឹង ៦២ ៨៩៧ ការងារ)។

ក្រាហ្វិក ៩៖ ទុនវិនិយោគតាមវិស័យ ៥ខែ ដើមឆ្នាំ២០២៤




*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

តារាង ៤៖ ស្ថានភាពវិនិយោគសរុប ឆ្នាំ២០២១, ២០២២, ២០២៣, និង ២០២៤

| អំឡុងពេល | ចំនួនគម្រោងវិនិយោគ | ទំហំទុនវិនិយោគ (លានដុល្លារ) | ការបង្កើតការងារថ្មី |
|---|---|---|---|
| ៥ខែ ឆ្នាំ២០២១ | 74 | 2,431 | 9,847 |
| ៥ខែ ឆ្នាំ២០២២ | 80 | 2,798 | 58,045 |
| ៥ខែ ឆ្នាំ២០២៣ | 75 | 649 | 82,724 |
| ៥ខែ ឆ្នាំ២០២៤ | 153 | 2,760 | 145,621 |

*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)*

### ១.៥. វិស័យទេសចរណ៍ក្នុងតំបន់អង្គរ / Angkor Park Tourism

យោងតាមទិន្នន័យការលក់បណ្ណទស្សនារមណីយដ្ឋានអង្គររបស់សហគ្រាសអង្គរបានបង្ហាញថា ក្នុងខែឧសភា ឆ្នាំ២០២៤ ឧទ្យានអង្គរបានទទួលភ្ញៀវបរទេសប្រមាណ ៥០,៨៧៩ នាក់ ដោយគិតជាប្រាក់ចំណូល បានប្រមាណ ២.២៨ លានដុល្លារ។ បើធៀបនឹងខែមុន ចំនួនភ្ញៀវទេសចរបរទេសទិញបណ្ណ និងចំណូលពីការលក់បណ្ណ បានធ្លាក់ ៣១,១០% និង ៣២,៤៥% រៀងគ្នា។ ការធ្លាក់ចុះនេះ គឺបណ្តាលមកពីកត្តារដូវកាល ដូចជាការចាប់ផ្តើមថយចុះនៃការធ្វើដំណើរបែបទេសចរណ៍ក្នុងអំឡុងពេលបើកវិស្សមកាល (Low-Season) ដែលធ្វើឱ្យចំនួនភ្ញៀវទេសចរបរទេសអាចនឹងបន្តធ្លាក់រហូតដល់ខែតុលា។

បើធៀបទៅនឹងខែឧសភាឆ្នាំ ២០២៣ ចំនួនភ្ញៀវទេសចរ និងចំណូលពីការលក់បណ្ណទស្សនារមណីយដ្ឋានអង្គរ បានកើនឡើង ១១,១៩% និង ១២,៥២% រៀងគ្នា។ ជាលទ្ធផល ក្នុងរយៈពេល ៥ខែដើមឆ្នាំ២០២៤នេះ រមណីយដ្ឋានអង្គរ បានទទួលភ្ញៀវទេសចរបរទេសសរុបប្រមាណ ៤៧២,២៥៨នាក់ កើន ៣៦,៩៨% ធៀបនឹង៥ខែឆ្នាំ២០២៣។

ក្រាហ្វិច ១០៖ ចំណូលភ្ញៀវបរទេសទិញបណ្ណទស្សនារមណីយដ្ឋានអង្គរ និងចំណូលពីការលក់បណ្ណ




*ប្រភព៖ គ្រឹះស្ថានអង្គរ*

## ១.៤. ស្ថានភាពសំណង់ / Construction

ក្នុងខែឧសភា ឆ្នាំ២០២៤ គម្រោងដែលទទួលបានការអនុញ្ញាតសាងសង់សរុប ២៣១ គម្រោង ដែលមានផ្ទៃក្រឡាសរុប ១ ៣៧៣ ពាន់ម៉ែត្រការ៉េ និងបានប្រើប្រាស់ទុនក្នុងទំហំ ៧៣៩,៧ លានដុល្លារ។ បើធៀបនឹងខែមុន ផ្ទៃក្រឡាសាងសង់ និងទំហំទឹកប្រាក់សាងសង់ មានការកើនឡើង ៤៩,៧% និង ១៥៩,៩% រៀងគ្នា ខណៈដែល ចំនួនគម្រោងសាងសង់មានការធ្លាក់ចុះប្រមាណ ៤៦ គម្រោង ស្មើនឹង ១៤,១%។

យោងតាមទិន្នន័យ រយៈពេល៥ខែ ឆ្នាំ២០២៤ គម្រោងទទួលបានការអនុញ្ញាតសាងសង់សរុប មានចំនួន ១ ៣៣០ គម្រោង ក្នុងនោះ មានគម្រោងលំនៅដ្ឋាន ១ ០៩៥ គម្រោង (មានបុរីចំនួន ១ ០៦១ គម្រោង និងខុនដូ ៣៤ គម្រោង), សំណង់ឧស្សាហកម្ម ៨៨ គម្រោង, សំណង់ពាណិជ្ជកម្ម ៩០ គម្រោង, សំណង់ទេសចរណ៍ ២១ គម្រោង, សំណង់សាធារណៈ ៣៥ គម្រោង និងសំណង់វិនិយោគ ១ គម្រោង។

ក្រាហ្វិក ១១៖ ផ្ទៃក្រឡាសាងសង់សរុបនិងអត្រាបម្រែបម្រួលក្នុងរយៈពេល ៥ខែ ចាប់គិតពី ២០២០-២០២៤



ក្រាហ្វិក ១២៖ ចំនួនសំណើសាងសង់សរុបនិងអត្រាបម្រែបម្រួលក្នុងរយៈពេល ៥ខែ ចាប់គិតពី ២០២០-២០២៤




ក្រាហ្វិក ១៣៖ ចំនួនគម្រោងនិងក្រឡាផ្ទៃ (ម៉ែត្រការ៉េ)




*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices

### ២.១. ថ្លៃប្រេងឥន្ធនៈ៖

ក្នុងខែឧសភា ឆ្នាំ២០២៤, ថ្លៃប្រេងឥន្ធនៈគិតជាមធ្យម (ថ្លៃប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូត) នៅលើទីផ្សារកម្ពុជា ថយ ៣,១% ធៀបនឹងខែមុន ក្នុងនោះ ប្រេងសាំងធម្មតាថ្លៃ ៤ ៣១៧ រៀល/លីត្រ (ថយ ៣,៤%) និងប្រេងម៉ាស៊ូតថ្លៃ ៤ ០៦៧ រៀល/លីត្រ (ថយ ២,៨%)។ ការថយចុះថ្លៃប្រេងឥន្ធនៈក្នុងស្រុក អាចបណ្តាលមកពីការថយចុះថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ។ ធៀបនឹងខែឧសភា ឆ្នាំ២០២៣, ថ្លៃប្រេងឥន្ធនៈគិតជាមធ្យម កើន ៤,៨% ក្នុងនោះ ថ្លៃប្រេងសាំងធម្មតា កើន ៤,៤% និងថ្លៃប្រេងម៉ាស៊ូត កើន ៥,២%។ ជាលទ្ធផល ក្នុងរយៈពេល ៥ខែដើមឆ្នាំ២០២៤ ប្រេងឥន្ធនៈក្នុងស្រុកគិតជាមធ្យមថ្លៃ ៤ ២៤០ រៀល/លីត្រ ថយ ០,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ក្នុងនោះ ថ្លៃប្រេងម៉ាស៊ូត ថយ ១,៣% ប៉ុន្តែថ្លៃប្រេងសាំងធម្មតា កើន ០,៧%។

ក្នុងខែឧសភា ឆ្នាំ២០២៤, ថ្លៃប្រេងឆៅគិតជាមធ្យមនៅលើទីផ្សារអន្តរជាតិស្ថិតក្នុងរង្វង់ ៨១,៥ ដុល្លារ/បារ៉ែល ធ្លាក់ ៧,៥% ធៀបនឹងខែមុន ក្នុងនោះ ប្រេងឆៅប្រភេទ Dubai ថ្លៃ ៨៣,៥ ដុល្លារ/បារ៉ែល (ធ្លាក់ ៦,៦%), ប្រេងឆៅ

ប្រភេទ Brent ថ្លៃ ៨២ ដុល្លារ/បារ៉ែល (ធ្លាក់ ៨,៨%), និងប្រេងឆៅប្រភេទ WTI ថ្លៃ ៧៨,៨ ដុល្លារ/បារ៉ែល (ធ្លាក់ ៦,៨%)។ គួរកត់សម្គាល់ដែរថា នេះជាខែដំបូងដែលតម្លៃប្រេងឆៅអន្តរជាតិគិតជាមធ្យមបានធ្លាក់ថ្លៃពី ៨៨,០ ដុល្លារ/បារ៉ែល ក្នុងខែមេសា ឆ្នាំ២០២៤ មកត្រឹម ៨១,៥ ដុល្លារ/បារ៉ែល ក្នុងខែឧសភា ឆ្នាំ២០២៤ ដែលបណ្តាលមកពីការថយចុះនៃតម្រូវការប្រើប្រាស់ប្រេងសកល។ ផ្អែកតាមការតាមដាន ទោះបីថ្លៃប្រេងឆៅអន្តរជាតិ មានការថយចុះក្នុងខែ ប៉ុន្តែថ្លៃប្រេងឆៅគិតជាមធ្យមក្នុងឆ្នាំ២០២៤ ហាក់នៅខ្ពស់នៅឡើយធៀបនឹងឆ្នាំមុន, ក្នុងនោះ ថ្លៃប្រេងឆៅគិតជាមធ្យម កើន ៩,៩% ធៀបនឹងខែឧសភា ឆ្នាំ២០២៣ និង កើន ៤,៥% ធៀបនឹងរយៈពេល ៥ខែដើមឆ្នាំ២០២៣។




*ប្រភព៖ ក្រសួងពាណិជ្ជកម្ម*




*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*

## ២.២. ថ្លៃអង្ករ៖

នៅលើទីផ្សាររាជធានីភ្នំពេញ ថ្លៃអង្ករជាមធ្យមក្នុងខែឧសភា ឆ្នាំ២០២៤ កើន ១,៧% ធៀបនឹងខែមុន ក្នុងនោះ អង្ករផ្កាម្លិះថ្លៃ ៤ ០៥៩ រៀល/គ.ក្រ (កើន ៤,៣%) និងអង្ករនាងមិញថ្លៃ ៣ ០៦៤ រៀល/គ.ក្រ (កើន ២,១%)។ ការកើនឡើងសន្សឹមៗនៃតម្លៃអង្ករក្នុងស្រុក អាចបណ្តាលមកពីបញ្ហាអាកាសធាតុ ដែលបានកាត់បន្ថយទិន្នផលដាំដុះស្រូវ-អង្ករ ស្រប ពេលដែលតម្រូវការក្រៅប្រទេសមានការកើនឡើង។ ផ្អែកតាមការតាមដាន ក្នុងរយៈពេល ៥ខែដើមឆ្នាំ២០២៤ ថ្លៃអង្ករជា

មធ្យម ស្ថិតក្នុងរង្វង់ ៣ ៤១៦ រៀល/គ.ក្រ កើន ១២,១% ឬ ៤០០ រៀល/គ.ក្រ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣ ក្នុងនោះ ថ្លៃអង្ករផ្កាម្លិះ និងថ្លៃអង្ករផ្កាខ្ញី កើន ៦,៦% និង ៨,៥% រៀងគ្នា។

នៅលើទីផ្សារអន្តរជាតិ ថ្លៃអង្ករគិតជាមធ្យមក្នុងខែឧសភា ឆ្នាំ២០២៤ ស្ថិតក្នុងរង្វង់ ៥៩៨,៩ ដុល្លារ/តោន កើនឡើង ៣,៩% ធៀបនឹងខែមុន ក្នុងនោះ អង្ករថៃប្រភេទបាក់ ៥% ថ្លៃ ៦២៨,០ ដុល្លារ/តោន (កើន ៦,១%), អង្ករថៃប្រភេទ A1 ថ្លៃ ៦០៦,៥ ដុល្លារ/តោន (កើន ៤,៩%), និងអង្ករថៃប្រភេទបាក់ ២៥% ថ្លៃ ៥៩៣,០ ដុល្លារ/តោន (កើន ៥,១%), ដោយឡែក អង្ករវៀតណាមប្រភេទបាក់ ៥% ថ្លៃ ៥៦៨,០ ដុល្លារ/តោន (ថយ ០,៦%)។ ការកើនឡើងយ៉ាងរហ័សនៃថ្លៃអង្ករអន្តរជាតិក្នុងខែឧសភា ឆ្នាំ២០២៤ អាចបណ្តាលមកពីការថយចុះនៃការផលិតស្រូវ ពីសំណាក់ប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ ដែលជាអ្នកផ្គត់ផ្គង់ស្រូវសំខាន់ៗទៅកាន់ទីផ្សារពិភពលោក ដោយសារការរងឥទ្ធិពលអវិជ្ជមានពីបាតុភូតធម្មជាតិ អែលនីញ្ញូ (El Nino) គួបផ្សំនឹងការបន្តកាត់បន្ថយការនាំចេញអង្កររបស់ប្រទេសឥណ្ឌា។ ផ្អែកតាមការតាមដាន ក្នុងរយៈពេល ៥ខែដើមឆ្នាំ២០២៤ ថ្លៃអង្ករអន្តរជាតិគិតជាមធ្យម ស្ថិតក្នុងរង្វង់ ៦០៤,៩ ដុល្លារ/តោន កើន ២៦,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣។




*ប្រភព៖ ការចុះស្រង់ថ្លៃទំនិញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋានគោលនយោបាយពីផ្សារចំនួន ៤ ក្នុងរាជធានីភ្នំពេញ*




*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*

**************

# ៣. ឧបសម្ព័ន្ធ

## ៣.១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia Economic Trends

### ៣.១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

| តារាង ៣.១.១.៖ ការប្រែប្រួលសន្ទស្សន៍ថ្លៃនៃក្រុមទំនិញទាំង ១២ ក្នុងខែឧសភា ឆ្នាំ២០២៤ គិតជា% | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បរិយាយ | ២០២៣ | | ២០២៤ | | ២០២៣ | | ២០២៤ | |
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | មេសា | ឧសភា | មេសា | ឧសភា | មេសា | ឧសភា | មេសា | ឧសភា |
| **មុខទំនិញគ្រប់មុខ** | 0.5% | 0.2% | 1.0% | 0.8% | 1.1% | 0.5% | 0.5% | 1.1% |
| ១. អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | 0.4% | 0.5% | 1.0% | 1.4% | 2.3% | 2.2% | 0.6% | 1.6% |
| ២. ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 0.1% | 1.1% | 1.2% | 0.1% | 1.0% | 1.9% | 1.0% | 0.0% |
| ៣. សំលៀកបំពាក់ និងស្បែកជើង | 0.5% | 0.5% | 1.0% | 1.4% | 2.1% | 2.1% | 1.6% | 2.5% |
| ៤. ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈដទៃទៀត | 0.8% | 0.4% | 0.5% | 0.4% | -1.1% | -1.2% | 0.0% | 0.1% |
| ៥. គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | 0.2% | 0.2% | 0.4% | 0.3% | 1.0% | 1.0% | 0.5% | 0.6% |
| ៦. សុខាភិបាល | 0.3% | 0.4% | 0.6% | 0.3% | -0.1% | 0.1% | 0.6% | 0.5% |
| ៧. ការដឹកជញ្ជូន | 1.4% | -2.0% | 1.3% | -2.4% | -3.6% | -8.7% | 0.0% | -0.4% |
| ៨. គមនាគមន៍ | 0.1% | 0.0% | 0.1% | 0.1% | -0.2% | -0.1% | 0.0% | 0.0% |
| ៩. ការកំសាន្ត និងវប្បធម៌ | 0.3% | 0.4% | 0.8% | 0.4% | 2.4% | 2.1% | 0.4% | 0.4% |
| ១០. ការសិក្សា | 0.0% | 0.0% | 1.0% | 0.4% | 1.2% | 1.2% | 2.6% | 2.9% |
| ១១. ភោជនីយដ្ឋាន | 0.5% | -0.1% | 1.4% | 0.6% | 0.9% | -0.6% | 0.1% | 0.8% |
| ១២. ទំនិញ និងសេវាកម្មផ្សេងៗ | 0.2% | 0.3% | 0.5% | 0.3% | 1.3% | 1.3% | 0.5% | 0.5% |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS)*

*សម្គាល់៖ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ៣.១.២. វិស័យពាណិជ្ជកម្ម / Trade

| តារាង ៣.១.២.៖ ការនាំចេញ និងការនាំចូលតាមមុខទំនិញសំខាន់ៗប្រចាំខែឧសភា ឆ្នាំ២០២៤ (លានដុល្លារអាមេរិក) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ២០២២ ៥ខែ | ២០២៣ ៥ខែ | ២០២៤ ៥ខែ | ២០២៤ | | | Δ% | | |
| | | | | កុម្ភៈ | មីនា | មេសា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៥ខែ) |
| តម្លៃនាំចេញសរុប (I) | 9,412 | 9,183 | 10,183 | 2,291 | 1,768 | 2,098 | 18.6% | 7.6% | 10.9% |
| តម្លៃនាំចេញសរុប (ដកមាសចេញ) | 9,293 | 8,731 | 10,073 | 2,276 | 1,744 | 2,067 | 18.5% | 16.0% | 15.4% |
| វាយនភណ្ឌ និងស្បែកជើង | 5,265 | 4,054 | 4,894 | 1002 | 809 | 1188 | 46.8% | 31.8% | 20.7% |
| កង់ | 374 | 229 | 131 | 27 | 30 | 32 | 9.1% | -32.0% | -43.1% |
| អង្ករ | 179 | 192 | 223 | 69 | 54 | 35 | -35.4% | -1.5% | 16.2% |
| ដំឡូងមី | 430 | 384 | 485 | 109 | 34 | 28 | -17.8% | 17.7% | 26.1% |
| ជ័រកៅស៊ូ | 149 | 133 | 185 | 26 | 24 | 33 | 38.1% | 37.9% | 39.6% |
| ទំនិញផ្សេងៗ | 2,896 | 3,739 | 4,156 | 1043 | 793 | 751 | -5.4% | 0.1% | 11.2% |
| តម្លៃនាំចូលសរុប (II) | 13,057 | 10,109 | 11,429 | 2,113 | 2,438 | 2,602 | 6.7% | 19.2% | 13.1% |
| តម្លៃនាំចូលសរុប (ដកមាសចេញ) | 10,727 | 10,109 | 11,266 | 2,100 | 2,430 | 2,602 | 7.1% | 19.2% | 11.4% |
| ក្រណាត់ | 2,280 | 1,832 | 2,226 | 361 | 500 | 597 | 19.4% | 43.5% | 21.5% |
| គ្រឿងសំណង់ | 802 | 752 | 926 | 155 | 184 | 229 | 24.5% | 29.4% | 23.1% |
| យានយន្ត | 539 | 460 | 485 | 103 | 97 | 109 | 12.4% | 29.9% | 5.2% |
| ប្រេងឥន្ធនៈ | 1,063 | 981 | 1,287 | 236 | 276 | 290 | 5.1% | 51.7% | 31.2% |
| ទំនិញផ្សេងៗទៀត | 6,042 | 6,084 | 6,343 | 1,244 | 1,373 | 1,377 | 0.3% | 4.8% | 4.3% |
| តុល្យភាពពាណិជ្ជកម្ម (I-II) | -3,645 | -926 | -1,247 | 178 | -670 | -504 | | | |

*ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

*សម្គាល់៖ ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៣. ស្ថានភាពវិនិយោគ / Investment

| តារាង ៣.១.៣.៖ ស្ថានភាពវិនិយោគក្នុងខែឧសភា ឆ្នាំ២០២៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០២៣ | ២០២៣ ៥ខែ | ២០២៤ ៥ខែ | ២០២៤ | | | Δ% | | |
| | | | | | មីនា | មេសា | ឧសភា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៥ខែ) |
| ចំនួនគម្រោង | គម្រោង | 268 | 75 | 153 | 37 | 22 | 25 | 3 | 15 | 78 |
| ចំនួនទុនវិនិយោគ | លាន($) | 4,927.6 | 648.6 | 2,759.5 | 817.90 | 309.57 | 246.30 | -20.4% | 308.7% | 325.4% |
| ចំនួនការងារបង្កើត | នាក់ | 307,553 | 82,724 | 145,621 | 39,922 | 23,382 | 15,139 | -35.3% | 10.2% | 76.0% |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

*សម្គាល់៖ ១) *គិតជាចំនួនគម្រោង ២)ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៤. ស្ថានភាពទេសចរណ៍ / Tourism

| តារាង ៣.១.៤.៖ ចំនួនភ្ញៀវអន្តរជាតិក្នុងខែឧសភា ឆ្នាំ២០២៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | ឯកតា | ២០២៣ | ២០២៣ | ២០២៤ | ២០២៤ | | | Δ% | | |
| | | | ៥ខែ | ៥ខែ | មីនា | មេសា | ឧសភា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៥ខែ) |
| ទេសចរបរទេសចូលមេណីយដ្ឋានអង្គរ | ពាន់នាក់ | 798.1 | 344.76 | 472.26 | 111.68 | 73.85 | 50.88 | -31.1% | 11.2% | 37.0% |
| ចំណូលពីសំបុត្ររបស់គ្រឹះស្ថានអង្គរ | លាន($) | 37,199 | 16.01 | 22.21 | 5.30 | 3.38 | 2.29 | -32.4% | 12.5% | 38.2% |

*ប្រភព៖ ក្រសួងទេសចរណ៍*

*សម្គាល់៖ ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.១.៥. ស្ថានភាពសំណង់ / Construction

| តារាង ៣.១.៥.៖ ស្ថានភាពសំណង់ក្នុងខែឧសភា ឆ្នាំ២០២៤ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០២៣ | ២០២៣ | ២០២៤ | ២០២៤ | | | Δ% | | |
| | | | ៥ខែ | ៥ខែ | មីនា | មេសា | ឧសភា | ខែមុន | ឆ្នាំមុន | ឆ្នាំមុន (៥ខែ) |
| សរុបចំនួនគម្រោង * | ចំនួន | 3,207 | 1,463 | 1,330 | 256 | 218 | 172 | -46 | -38 | -133 |
| សរុបផ្ទៃក្រឡា | ពាន់ម២ | 13,132 | 5,527 | 4,278 | 439 | 918 | 1,373 | 50% | 50% | -23% |
| សរុបដើមទុនប្រាក់ | លាន | 5,461 | 2,271 | 1,811 | 186 | 285 | 740 | 160% | 160% | -20% |

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

*សម្គាល់៖ ១) *គិតជាចំនួនគម្រោង ២)ក្នុងតារាង (,)ស្មើកាត់ខ្ទង់ និង (.)ស្មើក្បៀស*

## ៣.២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity Prices

| តារាង ៣.២.១.៖ ស្ថានភាពថ្លៃទំនិញសំខាន់ៗ (ថ្លៃមធ្យមប្រចាំខែ) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | | | ២០២៤ | | | Δ% | |
| | | | មីនា | មេសា | ឧសភា | មីនា | មេសា | ឧសភា | ខែមុន | ឆ្នាំមុន |
| ក្នុងស្រុក | សាំងធម្មតា | រៀល/លីត្រ | 4,250 | 4,367 | 4,133 | 4,300 | 4,467 | 4,317 | -3.4% | 4.4% |
| | ម៉ាស៊ូត | រៀល/លីត្រ | 4,167 | 4,100 | 3,867 | 4,167 | 4,183 | 4,067 | -2.8% | 5.2% |
| | ហ្គាស | រៀល/១៥គ.ក្រ | 76,580 | 76,560 | 76,850 | 76,300 | 76,450 | 76,350 | -0.1% | -0.7% |
| | អង្ករផ្កាម្លិះ | រៀល/គ.ក្រ | 3,667 | 3,674 | 3,682 | 3,803 | 3,893 | 4,059 | 4.3% | 10.2% |
| | អង្ករផ្កាខ្ញី | រៀល/គ.ក្រ | 2,676 | 2,826 | 2,813 | 3,342 | 3,370 | 3,310 | -1.8% | 17.7% |
| | អង្ករនាងមិញ | រៀល/គ.ក្រ | 2,841 | 2,674 | 2,671 | 2,971 | 3,000 | 3,064 | 2.1% | 14.7% |
| អន្តរជាតិ | Average Oil Price | រៀល/គ.ក្រ | 76.47 | 82.46 | 74.12 | 83.55 | 88.01 | 81.45 | -7.5% | 9.9% |
| | Brent | ដុល្លារ/បារ៉ែល | 78.53 | 84.11 | 75.70 | 85.45 | 90.05 | 82.00 | -8.9% | 8.3% |
| | Dubai | ដុល្លារ/បារ៉ែល | 77.52 | 83.83 | 75.08 | 84.70 | 89.39 | 83.53 | -6.6% | 11.3% |
| | WTI | ដុល្លារ/បារ៉ែល | 73.37 | 79.44 | 71.59 | 80.49 | 84.59 | 78.81 | -6.8% | 10.1% |
| | អង្ករថៃ (៥%) | ដុល្លារ/បារ៉ែល | 476.00 | 501.00 | 510.00 | 613.00 | 592.00 | 628.00 | 6.1% | 23.1% |
| | អង្កររៀតណាម (៥%) | ដុល្លារ/តោន | 444.64 | 455.10 | 470.53 | 585.43 | 571.50 | 567.97 | -0.6% | 20.7% |
| | អង្ករថៃ (២៥%) | ដុល្លារ/តោន | 468.00 | 490.00 | 495.00 | 584.00 | 564.00 | 593.00 | 5.1% | 19.8% |
| | អង្ករថៃ A.1 (100%) | ដុល្លារ/តោន | 460.91 | 482.88 | 492.68 | 607.72 | 577.95 | 606.47 | 4.9% | 23.1% |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS), ក្រសួងពាណិជ្ជកម្ម, World Bank, អ.គ.ប.*

## ៣.២.២ ស្ថានភាពថ្លៃប្រេងឥន្ធនៈនៅប្រទេសកម្ពុជា

**តារាង ៣.២.២ ថ្លៃលក់រាយប្រេងឥន្ធនៈនៅប្រទេសកម្ពុជា (ថ្លៃមធ្យមប្រចាំខែ និងប្រចាំឆ្នាំ)**

| ឈ្មោះទំនិញ | ឯកតា | ថ្លៃលក់រាយ (ថ្លៃមធ្យមប្រចាំឆ្នាំ) | | | | | | ថ្លៃលក់រាយ (ថ្លៃមធ្យមប្រចាំខែ) ៦ខែចុងក្រោយ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៥ខែ ដើមឆ្នាំ ២០២៤ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ ២០២៤ | មីនា ២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ |
| សាំងធម្មតា | ៛/លីត្រ | 3,623 | 3,000 | 3,888 | 4,800 | 4,326 | 4,297 | 4,200 | 4,167 | 4,333 | 4,300 | 4,467 | 4,317 |
| ប្រេងម៉ាស៊ូត | ៛/លីត្រ | 3,504 | 2,768 | 3,508 | 5,115 | 4,299 | 4,147 | 4,183 | 4,133 | 4,267 | 4,167 | 4,183 | 4,067 |
| ប្រេងឥន្ធនៈជាមធ្យម | ៛/លីត្រ | **3,564** | **2,884** | **3,698** | **4,958** | **4,312** | **4,222** | **4,192** | **4,150** | **4,300** | **4,233** | **4,325** | **4,192** |

**បម្រែបម្រួលថ្លៃប្រេងឥន្ធនៈនៅប្រទេសកម្ពុជា (រៀល/លីត្រ) និង (%)**

| ឈ្មោះទំនិញ | ឯកតា | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំឆ្នាំ (រៀល/លីត្រ) និង (%) | | | | | | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំខែ (រៀល/លីត្រ) និង (%) (៦ខែចុងក្រោយ) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៥ខែ ដើមឆ្នាំ ២០២៤ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ ២០២៤ | មីនា ២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ |
| សាំងធម្មតា | ៛/លីត្រ | - | - 623 | + 888 | + 913 | - 474 | - 29 | -250 | -33 | +167 | -33 | +167 | - 150 |
| | % | - | - 17.19% | + 29.58% | + 23.47% | - 9.88% | -0.66% | - 5.38% | -0.79% | +4.0% | -0.77% | +3.88% | - 3.36% |
| ប្រេងម៉ាស៊ូត | ៛/លីត្រ | - | - 736 | +740 | + 1,607 | - 817 | - 152 | - 50 | - 50 | +133 | -100 | +17 | -117 |
| | % | - | - 21.01% | + 26.75% | + 45.80% | - 15.96% | -3.53% | - 1.05% | -1.20% | +3.23% | - 2.34% | +0.40% | - 2.79% |
| ប្រេងឥន្ធនៈជាមធ្យម | ៛/លីត្រ | - | - 680 | + 814 | + 1,260 | - 645 | - 90 | -150 | - 42 | +150 | - 67 | +92 | -133 |
| | % | - | - 19.07% | + 28.22% | + 34.06% | - 13.02% | - 2.09% | - 3.18% | - 0.99% | +3.61% | - 1.55% | + 2.17% | - 3.08% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្ម*

## ៣.២.៣ ស្ថានភាពថ្លៃឆៅនៅលើទីផ្សារអន្តរជាតិ

តារាង ៣.២.៣ ថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (ថ្លៃមធ្យមប្រចាំខែ និងប្រចាំឆ្នាំ)

| ឈ្មោះទំនិញ | ឯកតា | ថ្លៃមធ្យមប្រចាំឆ្នាំ | | | | | | ថ្លៃមធ្យមប្រចាំខែ ៦ខែចុងក្រោយ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៥ខែ ឆ្នាំ ២០២៤ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ ២០២៤ | មីនា ២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ |
| ប្រេងឆៅ (Brent) | $/បារ៉ែល | 64.03 | 42.30 | 70.44 | 99.82 | 82.62 | 84.30 | 77.86 | 80.23 | 83.76 | 85.45 | 90.05 | 82.00 |
| ប្រេងឆៅ (WTI) | $/បារ៉ែល | 57.01 | 39.31 | 67.96 | 94.43 | 77.67 | 83.53 | 72.08 | 73.93 | 76.70 | 80.49 | 84.59 | 78.81 |
| ប្រេងឆៅ (Dubai) | $/បារ៉ែល | 63.18 | 42.17 | 68.81 | 97.05 | 81.98 | 78.90 | 77.22 | 78.86 | 81.18 | 84.70 | 89.39 | 83.53 |
| ប្រេងឆៅជាមធ្យម | $/បារ៉ែល | 61.41 | 41.26 | 69.07 | 97.10 | 80.76 | 82.24 | 75.72 | 77.67 | 80.55 | 83.55 | 88.01 | 81.45 |

បម្រែបម្រួលថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (ដុល្លារ/បារ៉ែល) និង (%)

| ឈ្មោះទំនិញ | ឯកតា | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំឆ្នាំ (ដុល្លារ/បារ៉ែល) និង (%) | | | | | | បម្រែបម្រួលថ្លៃប្រេងឥន្ធនៈប្រចាំខែ (ដុល្លារ/បារ៉ែល) និង (%) (៦ខែចុងក្រោយ) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ៥ខែ ដើមឆ្នាំ ២០២៤ | ធ្នូ ២០២៣ | មករា ២០២៤ | កុម្ភៈ២០២៤ | មីនា ២០២៤ | មេសា ២០២៤ | ឧសភា ២០២៤ |
| ប្រេងឆៅ (Brent) | $/បារ៉ែល | - | -21.73 | +28.14 | +29.38 | -17.21 | + 1.68 | -5.33 | +2.37 | +3.54 | +1.68 | +4.61 | -8.06 |
| | % | - | -33.94% | +66.53% | +41.71% | -17.24% | +2.03% | -6.40% | +3.04% | +4.41% | +2.01% | +5.39% | -8.95% |
| ប្រេងឆៅ (WTI) | $/បារ៉ែល | - | -17.71 | +28.66 | +26.47 | -16.76 | +5.86 | -5.35 | +1.85 | +2.77 | +3.79 | +4.10 | -5.78 |
| | % | - | -31.05% | +72.90% | +38.94% | -17.75% | +7.55% | -6.91% | +2.57% | +3.75% | +4.94% | +5.09% | -6.83% |
| ប្រេងឆៅ (Dubai) | $/បារ៉ែល | - | -21.01 | +26.64 | +28.24 | -15.07 | -3.08 | -6.23 | +1.64 | +2.32 | +3.52 | +4.69 | -5.86 |
| | % | - | -33.26% | +63.18% | +41.05% | -15.53% | -3.75% | -7.47% | +2.12% | +2.94% | +4.34% | +5.54% | -6.56% |
| ប្រេងឆៅជាមធ្យម | $/បារ៉ែល | - | -20.15 | +27.81 | +28.03 | -16.35 | +1.49 | -5.64 | +1.95 | +2.88 | +3.00 | +4.47 | -6.57 |
| | % | - | -32.81% | +67.41% | +40.58% | -16.83% | + 1.84% | -6.93% | +2.58% | +3.70% | +3.72% | +5.35% | -7.46% |

*ប្រភព៖ ធនាគារពិភពលោក (The Pink Sheet)*